**Program:** ឃាតកម្មមុនចូលគេង

**Topic:** Wayne Clifford BODEN
ឃាតកដែលគេឲ្យឈ្មោះថាជា បិសាចជញ្ជក់ឈាមបំពានផ្លូវភេទ

**Categories:** Crime Investigation

**Check**: **Pending**

**Content by:** Prey Reung

---

សូមស្វាគមន៏មកកាន់CamID Podcast!

គ្រាន់តែលឺថាបិសាចជញ្ជក់ឈាម អ្នកទាំងអស់គ្នាប្រាកដជាស្គាល់និងខ្លាចរអាបាត់ទៅហើយ ប៉ុន្តែថ្ងៃនេះព្រៃរឿងមិននិយាយរឿងបិសាចជញ្ជក់ឈាមនោះទេ។ អ្វីដែលព្រៃរឿងចង់លើកមកបកស្រាយថ្ងៃនេះគឺឃាតកដែលគេអោយឈ្មោះថា បិសាចជញ្ជក់ឈាមបំពានផ្លូវភេទនារីៗនៅប្រទេសកកាណាដាដែលរឿងរ៉ាវនេះកើតឡើងនៅចន្លោះឆ្នាំ ១៩៦៨ និង១៩៧២។ហេតុអ្វីបានជាគេដាប់ឈ្មោះដាឃាតកបិសាចជញ្ជក់ឈាមបំពានស្ត្រីយ៉ាងដូច្នោះ?តើគេពិតជាជញ្ជក់ឈាមមែនឬក៏យ៉ាងណា?

និយាយរឿងបិសាចជញ្ជក់ឈាម ធ្វើអោយសាច់រឿងវិលទៅដល់បុរសដែលមានមន្តស្នេហ៍ វ័យ២៦ឆ្នាំម្នាក់ ឈ្មោះថា Wayne Clifford BODEN។ Wayne កើតនៅក្នុងឆ្នាំ១៩៤៨ នៅក្នុងទីក្រុងDundas រដ្ឋOntario។នៅពាក់កណ្តាលឆ្នាំ១៩៦០ Wayne បានចូលរៀននៅវិទ្យាល័យមួយដែលមានឈ្មោះថាGlendal ស្ថិតនៅក្នុងស្រុកកំណើតរបស់គេ។គេជាមនុស្សម្នាក់ដែលចូលចិត្តភាពស្ងប់ស្ងាត់ មិនសូវនិយាយស្តីនោះទេ និងថែមទាំងមានរូបសម្រស់សង្ហា និងមានសាច់ដុំទៀតផង។ជារឿយៗWayne តែងតែណាត់ជួបសិស្សស្រីៗដែលរៀននៅសាលានោះ។ទន្ទឹមនឹងនោះ ទ្រព្យសម្បត្តិនៅក្នុងសាលាជាច្រើនក៏ត្រូវបានគេបំផ្លាញផងដែរ ព្រោះថាគេតែងតែមានជម្លោះវាយគ្នាជាមួយគូកនរបស់គេនៅក្នុងសាលា។

ព្រៃរឿងសូមបញ្ជាក់ជាមុនថា មិនមានប្រភពណាមួយបង្ហាញពីប្រវត្តរបស់ Wayneកាលពីនៅក្មេងក្បោះក្បាយនោះទេ។គួរអោយសោកស្តាយដែរ ដែលមិនមានប្រវត្តដាក់លាក់ពីឃាតកម្នាក់នេះ

គ្រាន់តែដឹងថាគេគឺជាមនុស្សប្រុសដែលមានមន្តស្នេហ៍ដូចដែលអ្នកទាំងអស់គ្នាឃើញនៅក្នុងរូបនេះហើយ ។

តាមការពិតទៅWayne ត្រូវបានគេអោយរហ័សនាមថាបិសាចជញ្ជក់ឈាមបំពានផ្លូវភេទក៏ដោយសារតែជនរងគ្រោះដែលត្រូវគេរំលោភនិងសម្លាប់ទាំងអស់សុទ្ធតែមានស្នាមខាំនៅលើដើមទ្រូង ។ហេតុដូចនេះទើបគេដាក់រហ័សនាមថាជាបិសាចជញ្ជក់ឈាម ។តាមរយៈស្នាមខាំនេះ បានធ្វើអោយប៉ូលិសសណ្ឋិដ្ឋានបានថាគ្រប់បទល្មើសទាំងអស់គឺមានជនបង្កតែមួយប៉ុណ្ណោះ ។ហើយជនរងគ្រោះដែលគេបានសម្លាប់គឺមានចំនួន៤នាក់ ។តើរឿងរ៉ាវនឹងទៅជាយ៉ាងណា ?

នៅថ្ងៃទី ៣ ខែតុលាឆ្នាំ ១៩៦៩ សាកសពជនរងគ្រោះម្នាក់ឈ្មោះថា Shirley Audette ត្រូវបានគេរកឃើញថាត្រូវបានគេបោះចោលនៅខាងក្រោយអគារផ្ទះល្វែងមួយនៅកណ្តាលទីក្រុងMontreal ។សម្លៀកបំពាក់របស់នាងមិនមានស្នាមដាច់រហែកនោះទេ ក៏ប៉ុន្តែនាងត្រូវបានឃាតកចាប់រំលោភនិងច្របាច់កសម្លាប់យ៉ាងសាហាវឃោឃៅ ព្រមទាំងមានបស្នាខាំនៅលើដើមទ្រូងរបស់នាងទៀតផង ។ នាងត្រូវបានស្លាប់យ៉ាងសោកសង្វេគ ។ក្រុមអ្នកកោសល្យវិច្ឆ័យបានរកឃើញថា នៅលើក្នុងក្រចកដៃរបស់នាងមិនមានឈាមនោះទេ ដោយផ្អែកលើមូលហេតុគេបានសន្និដ្ឋានថា នាងមិនបានតស៊ូ និងរើបម្រះចេញពីជនបង្កនោះទេ ។ អតីតមិត្តប្រុសម្នាក់របស់Shirleyបានប្រាប់ប៉ូលីសថា គាត់ជឿជាក់ថា នាងបានចូលរួមជាមួយបុរសដែលជាឃាតកនោះព្រោះថាបុរសម្នាក់នោះមានភាពទាក់ទាញទៅលើនាង ។ មិត្តប្រុសនាងបាននិយាយទៀតថា នាងកំពុង“តែដើរចូលទៅក្នុងអ្វីដែលគ្រោះថ្នាក់ហើយ” ។ កាលពីនាងនៅរស់ នាងមិនដែលនិយាយពីឈ្មោះរបស់បុរសនោះទេ ។ ផ្អែកតាមបទសម្ភាសន៍នេះ ប៉ូលីសបានសន្មត់ថាឃាតកប្រាកដជាមានការទាក់ទាញស្រីៗដើម្បីទៅរួមមេត្រីជាមួយនិងគេហើយ ។យ៉ាងណាប៉ូលិសមិនទាន់អាចកំណត់អត្តសញ្ញាណជនបង្កនោះទេ ។

លុះដល់ថ្ងៃទី២៣ ខែវិច្ឆិកា គឺមានរយៈពេលមួយខែពីការស្លាប់របស់Shirley មាននារីម្នាក់ឈ្មោះថា Marielle Archambault ដែលជាអ្នកលក់គ្រឿងអលង្កាម្នាក់ បានចេញពីកន្លែងការងារជាមួយបុរសវ័យក្មេងម្នាក់នៅម៉ោងសំពក ។នាងបានណែនាំទៅកាន់និយោកជករបស់នាងថា បុរសម្នាក់នោះមានឈ្មោះBill ដែលពេលនោះ មើលទៅនាងហាក់បីដូចជាសប្បាយខុសប្លែកពីធម្មតា ។

ផ្ទុយទៅវិញ ស្រាប់តែព្រឹកស្អែកស្រាប់តែនាងមិនមានវត្តមាននៅកន្លែងធ្វើការនោះទេ ។ ដោយមានការមន្ទិលសង្ស័យ និយោជករបស់ Marielle ក៏បានទៅពិនិត្យនាងនៅក្នុងផ្ទះល្វែងរបស់នាងដើម្បីអោយដឹងថានាងឈឺឬក៏យ៉ាងណា ។ក៏ប៉ុន្តែរូបភាពជាក់ស្តែង មិនដូចអ្វីដែលពួកគេគិតនោះទេ ។និយោកជកទាំងនោះបែរជារកឃើញសាកសពរបស់Marielle ដោយគ្មានខោអាវរុំនៅក្នុងភួយ នៅក្នុងបន្ទប់ទទួលភ្ញៀវរបស់នាង ។យ៉ាងណាមុនពេលដែលនាងបានស្លាប់ នាងក៏បានរើបម្រះពីជនបង្កដែរ តែមិនឈ្នះជនបង្កនោះទេ ។នាងត្រូវបានឃាតកចាប់បំពាននាងយ៉ាងសាហាវព្រៃផ្សៃ និងមិនទុកជីវិតអោយនាងនោះទេ ។នៅលើដើមទ្រូងរបស់នាងក៏ឃើញមានស្នាមខាំផងដែរ ។ ប៉ូលីសបានរកឃើញរូបថតដែលរហែកខ្ទេចខ្ទីនៅក្នុងអាផាតមិនរបស់  Marielle ដែលនេះគឺជាស្នាដៃជនបង្កដែលត្រូវបានកំណត់អត្តសញ្ញាណថាជា“Bill” ដោយមិត្តរួមការងាររបស់នាង ។ តែតាមការពិតBillគ្រាន់តែឈ្មោះនៅក្នុងក្តីស្រមើស្រម៉ៃរបស់ពួកនិយោកជកទាំងនោះតែប៉ុណ្ណោះ គ្មានBillណាមកសម្លាប់Marielleនោះទេ គឺមានតែWayneតែប៉ុណ្ណោះ ។ទោះយ៉ាងណាក៏ដោយក៏ប៉ូលីសមិនអាចភ្ជាប់រូបថតដែលរហែកទាំងនោះ អោយត្រូវមួយជនសង្ស័យណាម្នាក់ឡើយ

សូម្បីតែតាមរយៈគំនូរព្រាងរបស់ប៉ូលីសដែលផ្អែកលើរូបភាពត្រូវបានចែកចាយសម្រាប់ការបោះពុម្ពផ្សាយនៅក្នុងកាសែត។

ឈ្មោះថាBillនៅតែជាចម្ងល់របស់ប៉ូលិសដដែរ រហូតមកដល់២ខែក្រោយមក គេបានធ្វើសកម្មភាពម្តងទៀត។នៅថ្ងៃទី ១៦ ខែមករា ឆ្នាំ១៩៧ នារីម្នាក់ឈ្មោះថា Jean Way អាយុ ២៤ ត្រូវបានមិត្តប្រុសនាងឈ្មោះថាBrianមកទទួលនាងដើម្បីណាត់ជួបនាងនៅឯផ្ទះរបស់នាងនៅលើផ្លូវលីនខុននៅកណ្តាលទីក្រុងMontreal។ នៅពេលBrianមកដល់ក៏គោះទ្វាផ្ទះរបស់នាង តែគ្មានអ្នកណាឆ្លើយតបនោះទេ ដូច្នេះBrianក៏សម្រេចចិត្តថានឹងមកយកនាងនៅពេលក្រោយ។

ក៏ប៉ុន្តែពេលត្រលប់មកវិញមិត្តប្រុសរបស់នាងបែរជាឃើញទ្វារផ្ទះនាងត្រូវបានបើក ហើយក៏បានឃើញសាកសពអាក្រាតរបស់នាងនៅលើសាឡុង ចំណែកឯដើមទ្រូងរបស់នាងត្រូវបានឃាតកខាំយ៉ាងខ្ទិចខ្ទី។ វាហាក់បីដូចជាឃាតករបានស្ថិតនៅក្នុងផ្ទះរបស់នាងរួចជាស្រេច អំឡុងពេលដែលBrian កំពុងគោះទ្វារពីដំបូង។ ចំណែកឯការធ្វើកោសល្យវិច័យដោយវេជ្ជបណ្ឌិតJean-Paul Valcourt បានរកឃើញសក់ពីរសសៃនៅក្នុងក្រចកដៃខាងឆ្វេងរបស់នាង ដែលបង្ហាញថាជនរងគ្រោះពិតជាបានព្យាយាមរើបម្រះចេញពីឃាតកពិតមែន។ ក្រោយពីកើតហេតុ ការផ្សព្វផ្សាយជាសាធារណៈពីឃាតកម្មក៏បានធ្វើឡើង ហើយក៏បានបង្កភាពភ័យខ្លាចទៅដល់អ្នករស់នៅក្នុងទីក្រុង។ ប៉ុន្តែវាបានប្រែក្លាយថាឃាតកម្មរបស់Jean Way គឺជាឃាតកម្មចុងក្រោយនៅក្នុងទីក្រុងនោះព្រោះថា“Bill” បានបាត់ខ្លួន។មួយឆ្នាំក្រោយមក ដំណឹងឃាតកម្ម ក៏លិចលឺម្តងទៀតនៅទីក្រុងផ្សេងទៀតដែលមានចម្ងាយប្រហែល២៥០០ម៉ាលពីទីក្រុងMontreal។

ជនរងគ្រោះចុងក្រោយ គឺមានឈ្មោះថា Elizabeth Anne Porteous អាយុ៣៣ឆ្នាំ និងជាគ្រូបង្រៀនម្នាក់ ។រឿងរ៉ាវនេះកើតឡើងនៅក្នុងទីក្រុង Calgary ពោលគឺនៅពេលដែលElizabethមិនមានវត្តមាននៅកន្លែងធ្វើការ នៅព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៧១ ។ម្ចាស់Apartment របស់នាងត្រូវបានគេហៅសួរ ហើយក៏បានរកឃើញសាកសពរបស់ Elizabeth ស្លាប់នៅក្នុងបន្ទប់គេងរបស់នាង ។មកដល់ចំណុចនេះ ព្រៃរឿងសូមបញ្ជាក់ផងដែរ Apartment ដែលនាងស្នាក់នៅនោះ ក៏ជាកន្លែងApartment ដែល Marielle Archambault ស្នាក់នៅដែរ ។កន្លែងApartment នោះក៏ក្លាយទៅជាសញ្ញានៃការសង្ស័យចំបងរបស់ប៉ូលិស និងជាកន្លែងដែលរំលោភនិងសម្លាប់របស់ឃាតក ព្រមទាំងដើមទ្រូងរបស់ Elizabeth ក៏មានស្នាមដាច់រលាត់ដោយសារតែឃាតកខាំដែរ ។ក្រៅពីនេះប៉ូលិសក៏បានរកឃើញឡេវអាវដែលរបូត ចេញពីអាវឃាតកផងដែរ ។

នៅក្នុងការស៊ើបអង្កេតរបស់ក្រុមប៉ូលិសអំពីឃាតកម្មនេះ ប៉ូលីសបានទទួលដំណឹងពីមិត្តរួមការងាររបស់នាងពីរនាក់ថា ពួកគេនាងបានឃើញនៅកន្លែងភ្លើងស្តុបជិះរថយន្ត Mercedes ពណ៌ខៀវនៅយប់ដែលនាងស្លាប់ ។ រថយន្តនេះត្រូវបានគេរាយការណ៍ថាមានតែមសញ្ញារូបគោដែលបិទនៅកញ្ចក់ខាងក្រោយ ។ មិត្តភក្តិរបស់ជនរងគ្រោះម្នាក់ក៏បានប្រាប់ប៉ូលីសដែរថាថ្មីៗនេះនាងបានណាត់ជួបបុរសម្នាក់ឈ្មោះ“ Bill” ដែលត្រូវបានគេពណ៌នាថាជា អ្នកស្លៀកពាក់ត្រឹមត្រូវនិងស្លូតបូត ហើយមានសក់ខ្លី ។ តាមរយៈឈ្មោះថា Billនេះហើយធ្វើអោយប៉ូលិសដាក់ការសន្និដ្ឋានយ៉ាងច្បាស់ថា ការស្លាប់របស់Elizabeth ប្រាកដជាមានទំនាក់ទំនងជាមួយនឹងអំពើឃាតកម្មនៅទីក្រុងMontreal ហើយ ។

នៅថ្ងៃបន្ទាប់គឺនៅថ្ងៃទី ១៩ ខែឧសភា រថយន្ត Mercedes ពណ៌ខៀវនេះត្រូវបានក្រុមប៉ូលិសល្បាតប្រទះឃើញចតនៅក្បែរកន្លែងកើតហេតុ។ ច្បាស់ណាស់រថយន្តនោះគឺជារបស់ Wayne ។Wayneក៏ត្រូវបានប៉ូលិសចាប់ខ្លួនមួយម៉ោងកន្លះក្រោយមក ខណៈដែលគេដើរទៅឡានរបស់គេវិញ។ គេបានប្រាប់ប៉ូលីសថាគេបានរើចេញពីទីក្រុងMontreal កាលពីមួយឆ្នាំមុនហើយបានសារភាពថាគេបានណាត់ជួបElizabeth ហើយនៅជាមួយនាងនៃយប់ឃាតកម្មនោះ។ នៅពេលដែលប៉ូលិសបានបង្ហាញខ្សែរអាវដែលរកឃើញនៅកន្លែងកើតហេតុនោះ គេបានសារភាពថាវាជាកម្មសិទ្ធិរបស់គេ។ ទោះយ៉ាងណាក៏ដោយ Wayne បាននិយាយថាElizabethមិនអីនោះទេមុនពេលដែលគេចាកចេញពីនាងនៅយប់នោះ។

ប៉ូលីសនៅទីក្រុងCalgaryក៏បានកាន់រូបថតដែលបានរកឃើញពីApartmentរបស់Shirley ទៅប្រៀបធៀបជាមួយWayne។ដោយសារWayneប្រហាក់ប្រហែលនឹងបុរសនៅក្នុងរូបថតនោះ ប៉ូលិសក៏បានឃុំខ្លួនគេពីបទសង្ស័យថាបានធ្វើឃាតកម្មលើមនុស្សស្លូតត្រង់។ បន្ទាប់មកពួកប៉ូលិសទាំងនោះក៏បានផ្តោតទៅលើស្នាមខាំដែលមានលើជនរងគ្រោះម្តង។

ម្តងនេះក្រុមប៉ូលិសក៏បានលើករឿងស្នាមខាំនេះទៅអោយវេជ្ជបណ្ឌិតម្នាក់ដែលមានឈ្មោះថាGordon Swann ដើម្បីអោយលោកGordon យកមកសិក្សាថាស្នាមខាំទាំងប៉ុន្មានដែលមាននៅលើដើមទ្រូងនិងលើករបស់ជនរងគ្រោះគឺជាស្នាមខាំរបស់Wayne។ដោយសារតែនៅប្រទេសកាណាដា មិនមានអ្នកជំនាញពិនិត្យទៅលើស្នាមខាំនេះ Gordon ក៏បានសរសេរសំបុត្រមួយច្បាប់ទៅកាន់ភ្នាក់ងារស៊ើបអង្កេតរបស់FBI ដើម្បីសុំជំនួយ។ហើយGordon

ក៏ទទួលសារតេបពីភ្នាក់ងារFBIម្នាក់ឈ្មោះថា Edgar Hoover។
Edgarក៏បានណាត់Gordonអោយទៅជួបគាត់នៅប្រទេសអង់គ្លេស។

នៅទីបំផុតGordonក៏អាចទទួលបានព័ត៌មានដែលគាត់ត្រូវការនិងផ្អែកលើការស្នាមខាំពីធ្មេញរបស់Wayne។Gordonបានបង្ហាញពីភាពស្រដៀងគ្នាចំនួន ២៩ ចំណុចរវាងស្នាមខាំនៅក្នុងខ្លួនរបស់Elizabeth និងធ្មេញWayne។ភស្តុតាងទាំងនេះគឺគ្រប់គ្រាន់សម្រាប់គណៈវិនិច្ឆ័យនៃការជំនុំជម្រះក្តីរបស់Wayne ហើយដើម្បីរកឃើញថាគេមានទោសពីបទឃាតកម្មដែលគេនឹងត្រូវប្រឈមមុខនឹងការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

ចុងក្រោយ Wayne Clifford Boden ក៏ត្រឡប់ទៅកាន់ទីក្រុងMontreal វិញដើម្បីប្រឈមជាមួ ួយនិងកិច្ចជនុំជម្រះក្តីនៅទីនោះ។ទីបំផុតគេបានសារភាពថាគេពិតជាប្រព្រឹត្តអំពើឃាតកម្មប៉ុន្តែមានតែ៣ឃាតកម្មប៉ុណ្ណោះដែលគេទទួលស្គាល់។ប៉ុន្តែគេបានបដិសេធការជាប់ពាក់ព័ន្ធនឹងការស្លាប់របស់ជនរងគ្រោះម្នាក់ឈ្មោះថាNorma Vaillancourtដែលជានិស្សិតអាយុ ២១ ឆ្នាំនិងត្រូវបានគេសម្លាប់នៅថ្ងៃទី ២៣ ខែកក្កដាឆ្នាំ ១៩៦៨។ Wayneក៏ត្រូវបានគេសង្ស័យថាជាប់ពាក់ព័ន្ធនៃឃាតកម្មនោះ។Wayne ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារចំនួន ៣ ជីវិតហើយគេត្រូវបានបញ្ជូនទៅពន្ធនាគារKingstoneដែលជាកន្លែងដែលគេចាប់ផ្តើមអនុវត្តទោសនៅថ្ងៃទី ១៦ ខែកុម្ភះឆ្នាំ ១៩៧២ ។នៅឆ្នាំ១៩៧៧ ក្រោយពីគេបានជាប់ពន្ធធនាគារអស់រយះពេល៥ឆ្នាំ Wayne បានរត់គេចចេញពីពន្ធធនាគារបានសម្រេច ក៏ប៉ុន្តែ៣៦ម៉ោងក្រោយមកក៏ត្រូវបានប៉ូលិសចាប់ខ្លួនបានវិញ។Wayne ក៏បានបាត់បង់ជីវិតនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៦ ដោយសារតែជម្ងឺមហារីកស្បែក។

តាមរយៈសាច់រឿងខាងលើ យើងអាចសិក្សាបានថា ស្ត្រីគ្រប់រូបគួរតែចេះប្រយ័ត្ននិងការពារខ្លួនដោយសេចក្តីភ្ញាក់រលឹកជានិច្ច ព្រោះថានៅក្នុងសង្គមមានមនុស្សខិលខូចច្រើនណាស់ដែលចាំបៀតបៀនយើង ។អ្វីដែលសំខាន់នោះគឺថា មិនត្រូវមើលមនុស្សតែសំបកក្រៅនោះទេ ។សូមស្តាប់ដោយការត្រិះរិះពិចារណា!

Links and Resources

https://murderpedia.org/male.B/b/boden-wayne.htm
https://alchetron.com/Wayne-Boden
https://peoplepill.com/people/wayne-boden/lists